ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តសៀមរាប**

-សំណុំរឿងរដ្ឋប្បវេណីលេខ៖៨៣៩
ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៧
-សញ្ញាណរឿងក្តី៖ជំនុំជម្រះសាជាថ្មី
-សាលក្រមរដ្ឋប្បវេណីលេខ៖២៩ "គ"
ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៨

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តសៀមរាប

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៨។

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រម សាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តសៀមរាប

សហដើមចោទ៖(១).ឈ្មោះ [redacted] **ឈឿម** ភេទប្រុស អាយុ ៧០ ឆ្នាំ (២).ឈ្មោះ [redacted] **ណាំ** ភេទស្រី អាយុ ៦៨ ឆ្នាំ និង(៣).ឈ្មោះ [redacted] **ខេង** ភេទប្រុស អាយុ ៣៤ឆ្នាំ ដែលមានអាសយដ្ឋាននៅភូមិចុង [redacted] ។

អ្នកតំណាងដោយអាណត្តិឱ្យសហដើមចោទ៖ លោកមេធាវី [redacted] អត្តលេខ:១៦៦៦T មានការិយាល័យនៅ [redacted], លោកមេធាវី [redacted] អត្តលេខ:១៣០៤ មានអាសយដ្ឋាននៅ [redacted] និង លោកមេធាវី [redacted] អត្តលេខ:១១៦៧ មានការិយាល័យផ្ទះ [redacted] ។

សហចុងចម្លើយ៖(១).ឈ្មោះ [redacted] **គឹមឈឿប** ភេទប្រុស អាយុ៦៩ ឆ្នាំ (២).ឈ្មោះ [redacted] **គឹម ឆង** ភេទប្រុស អាយុ ៦៣ ឆ្នាំ (៣).ឈ្មោះ [redacted] **គឹមឈន់** ភេទស្រី អាយុ៦៦ឆ្នាំ ដែលមានអាសយដ្ឋាននៅ [redacted] និង (៤).ឈ្មោះ [redacted] **ឡុម** ភេទប្រុស អាយុ៧៣ ឆ្នាំ ដែលមានទីលំនៅភូមិ [redacted] ។

### ១-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ:

១.១-ប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រមរដ្ឋប្បវេណីលេខ:២២ "ខ" ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦, លេខ:២៣ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ និងលេខ: ២៤ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០០៦ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។



Scanned with CamScanner

១.២-សុំបដិសេធចោលនូវសេចក្តីសម្រេចទាំងមូលនៃសាលក្រមរដ្ឋប្បវេណីលេខ: ២២ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦, លេខ:២៣ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ និងលេខ: ២៤ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ២០០៦ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

១.៣-សុំលុបចោលការអនុវត្តដោយបង្ខំលើសំណុំរឿងអនុវត្តដោយបង្ខំលេខ:១៦, លេខ:១៧ និងលេខ: ១៨ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ។

១.៤-សុំទទួលស្គាល់លើកម្មសិទ្ធិនៅលើក្បាលដីលេខ:**២៦៥** មានទីតាំងស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ជារបស់ឈ្មោះម្ចាស់ដី: [redacted] ឈឿម និងឈ្មោះ [redacted] ឡាយ ដែលមានព្រំប្រទល់ខាងជើង: ផ្លូវ, ខាងត្បូង:ផ្លូវ, ខាងកើត:ឈ្មោះ [redacted] ឈឹមឆន(២៦៦) និងខាងលិច: [redacted] ណាំ (២៧១) ;ផ្លូវ, ក្បាលដីលេខ:**២៧១** មានទីតាំងស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ជារបស់ឈ្មោះម្ចាស់ដី: [redacted] ណាំ ដែលមានព្រំប្រទល់ខាងជើង:ឈ្មោះ [redacted] ប៉ាយយ៉ុម(២៦៤), ខាងត្បូង:ផ្លូវ, ខាងកើត [redacted] ឡាយ (២៦៥) និង ខាង លិច: [redacted] ខេង (២៧២) និងក្បាលដីលេខ:**២៧២** មានទីតាំងស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ជារបស់ឈ្មោះម្ចាស់ដី: [redacted] **ខេង** និងឈ្មោះ [redacted] ស្រីពេជ្រ ដែលមានព្រំប្រទល់ខាងជើង:ឈ្មោះ [redacted] ប៉ាយយ៉ុម (២៦៤), ខាងត្បូង:ផ្លូវ, ខាងកើត:ឈ្មោះ [redacted] ណាំ (២៧១) និងខាងលិច (៣៧៦) ចេញដោយមន្ត្រីវាស់វែងនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប ។

## ២-អង្គហេតុនិងចំណុចវិវាទ

### ២.១-ការសង្ខេបរឿងក្តី

ក្នុងរឿងនេះ សហដើមចោទបានកាន់កាប់ដីលំនៅដ្ឋានចំនួន២០ម៉ែត្រ គុណ ៤០ម៉ែត្រ ស្មើនឹង០៤(បួន)ប្លង់ ដែលមានទីតាំងស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប តាំងពីឆ្នាំ១៩៨៩មកម្ល៉េះ ដោយបានធ្វើពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៨ ដោយពុំដែលឃើញសហចុងចម្លើយខាងលើ មកស្នាក់នៅនិងបង្កបង្កើនផល ឬអាស្រ័យផលលើដីខាងលើនេះម្តងណាឡើយ ហើយសហចុងចម្លើយពុំដែលស្គាល់អ្នកទាំងនោះដែរ ។ ក្រោយមកសហដើមចោទបានធ្វើលិខិតអះអាងប្រវត្តដី ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ ដែលមានសាក្សីមានដីជាប់ព្រំគ្នា និងបានចុះហត្ថលេខាប្រថាប់ត្រា ដោយលោកមេភូមិ មេឃុំត្រឹមត្រូវ ។ ក្នុងឆ្នាំ ២០១៦ មន្ត្រីសុរិយោដីបានចុះវាស់វែងចុះបញ្ជីធ្វើប្លង់រឹងជាលក្ខណៈប្រព័ន្ធ ។ បន្ទាប់ពីវាស់វែងរួច ខាងមន្ត្រីសុរិយោដីក៏បានចេញបង្កាន់ដៃឱ្យសហដើមចោទមករក្សាទុក ដើម្បីទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ(ប្លង់រឹង) ដែលមានលេខក្បាលដី ២៦៥ (ទំហំ២០ម៉ែត្រ គុណ ៨០ម៉ែត្រ) ស្មើនឹង២ប្លង់, ក្បាលដីលេខ:២៧១(ទំហំ ២០ម៉ែត្រ គុណ ៤០ម៉ែត្រ ) ស្មើនឹង១ប្លង់ និងក្បាលដីលេខ:២៧២ (ទំហំ ២០ម៉ែត្រ គុណ ៤០ម៉ែត្រ) ស្មើនឹង១ប្លង់ ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦ ។ ស្រាប់តែថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០១៧ សហដើមចោទទើបដឹងដំណឹងថាតំណាងអយ្យការនិងជាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា នឹងចុះមកអនុវត្តដោយបង្ខំចំពោះសាលក្រមរដ្ឋប្បវេណីលេខ:២២ "ខ",លេខ: ២៣ "ខ" និងលេខ:២៤ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ វេលាម៉ោង៨,០០នាទីព្រឹក ។ ដោយការចុះអនុវត្តដោយ

បង្គំរបស់តំណាងអយ្យការ និងជាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា គឺធ្វើឱ្យប៉ះពាល់ដល់សិទ្ធិលើកម្មសិទ្ធិ ឬសិទ្ធិផ្សេងៗទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬការប្រគល់ចំពោះវត្ថុនៃការអនុវត្តដោយបង្ខំខាងលើរបស់សហដើមចោទ សហដើមចោទ ក៏រៀបចំដាក់ពាក្យបណ្តឹងតវ៉ាជាតតិយជន ប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលក្រមរដ្ឋប្បវេណីស្ថាពរលេខ: ២២ "ខ", លេខ: ២៣ "ខ" និង លេខ:២៤ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យឡើងវិញ និងទាមទារសុំឱ្យតុលាការចេញសាលក្រមដូចខាងលើ ។

## ២.២-ការអះអាងរបស់ភាគីស្តីពីការទាមទារ

### ២.២.១.ការអះអាងរបស់សហដើមចោទ

-លោកមេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថា ក្នុងនាមខ្លួនជាអ្នកតំណាងដោយអាណត្តិឱ្យសហដើមចោទ ខ្លួនធ្វើសេចក្តីថ្លែងការណ៍អះអាងអំពីកម្មវត្ថុបណ្តឹងដែលខ្លួនបានធ្វើការទាមទារដូចខាងក្រោម៖

១-អំពីការសុំទាមទារ ត្រង់ចំណុចទី១. សុំទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលក្រមរដ្ឋប្បវេណីលេខ:២២ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០០៦, លេខ:២៣ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ និងលេខ:២៤ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០០៦ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ដោយហេតុថាតុលាការបានពិចារណារួចហើយ ដូចមានសំអាងហេតុក្នុងដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មីលេខ:៤៧៩ /២០១៨ ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៨ ដោយយោងតាមបញ្ញត្តិមាត្រា៣១៨ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានចែងថា: បើដើមចោទ និង ចុងចម្លើយ បានទទួលនូវសាលក្រម ឬ សាលដីកា ដោយរួមគំនិតគ្នាក្នុងគោលបំណងធ្វើឱ្យបាត់បង់សិទ្ធិ ឬផលប្រយោជន៍របស់តតិយជន តតិយជននោះ អាចធ្វើឧបាស្រ័យ ដោយបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលក្រម ឬសាលដីកាចុងក្រោយដែលបានចូលជាស្ថាពរនោះបាន ។

២-អំពីការទាមទារត្រង់ចំណុចទី២.សុំបដិសេធចោលនូវសេចក្តីសម្រេចទាំងមូល នៃសាលក្រមរដ្ឋប្បវេណីលេខ: ២២ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦, លេខ:២៣ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ និងលេខ: ២៤ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០០៦ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ដោយហេតុថា:ខ្លឹមសារនៃសេចក្តីសម្រេចទាំងមូលនៃសាលក្រមរដ្ឋប្បវេណីទាំងបីខាងលើនេះ បានធ្វើការសម្រេចដោយបានបំពានសិទ្ធិ និងខូចខាតប្រយោជន៍របស់សហដើមចោទយ៉ាងធ្ងន់ធ្ងរ ហើយមូលហេតុដែលទាមទារឱ្យតុលាការជំនុំជម្រះសាជាថ្មី គឺតុលាការបានទទួលស្គាល់ហើយថាពិតជាមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីប្រាកដមែន ដូចមានក្នុងសំអាងហេតុចំណុច១ ខាងលើ ។

១.៣-អំពីការទាមទារ ត្រង់ចំណុចទី៣.សុំលុបចោលការអនុវត្តដោយបង្ខំលើសំណុំរឿងអនុវត្តដោយបង្ខំលេខ:១៦, លេខ:១៧ និងលេខ:១៨ ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ដោយមូលហេតុថាការចុះអនុវត្តដោយបង្ខំរបស់តំណាងអយ្យការ និងជាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា គឺធ្វើឱ្យប៉ះពាល់ដល់សិទ្ធិលើកម្មសិទ្ធិ ឬសិទ្ធិផ្សេងៗទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬការប្រគល់ចំពោះវត្ថុនៃការអនុវត្តដោយបង្ខំខាងលើរបស់សហដើមចោទ ។

៤-អំពីការទាមទារត្រង់ចំណុចទី៤.សុំទទួលស្គាល់លើកម្មសិទ្ធិនៅលើក្បាលដីលេខ:**២៦៥** មានទីតាំងស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ជារបស់ឈ្មោះម្ចាស់ដី: [redacted] ឈឿម និង [redacted] ឡាយ ដែលមានព្រំប្រទល់ខាងជើង:ផ្លូវ, ខាងត្បូង:ផ្លូវ, ខាងកើត:ឈ្មោះ[redacted]ឃឹមឆន(២៦៦) និងខាងលិច:[redacted] លាំ (២៧១) ; ផ្លូវ , ក្បាលដីលេខ:**២៧១** មានទីតាំងស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ជារបស់ឈ្មោះម្ចាស់ដី: [redacted] លាំ ដែលមានព្រំប្រទល់ខាងជើង:ឈ្មោះ [redacted] ប៉ាយយ៉ុម(២៦៤), ខាងត្បូង:ផ្លូវ, ខាងកើត:[redacted] ឡាយ (២៦៥) និង ខាងលិច:[redacted]ខេង (២៧២) និងក្បាលដីលេខ:**២៧២** មានទីតាំងស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ជារបស់ឈ្មោះម្ចាស់ដី: [redacted] **ខេង** និងឈ្មោះ[redacted]ស្រីពេជ្រ ដែលមានព្រំប្រទល់ខាងជើង: ឈ្មោះ [redacted] ប៉ាយយ៉ុម(២៦៤), ខាងត្បូង:ផ្លូវ, ខាងកើត:ឈ្មោះ[redacted] លាំ (២៧១) និងខាងលិច (៣៧៦) ចេញដោយមន្ត្រីវាស់វែងនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប ដោយហេតុថាសហដើមចោទមានបង្កាន់ដៃក្បាលដីដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចត្រឹមត្រូវតាមច្បាប់ ហើយបញ្ជាក់លេខក្បាលដីនិងឈ្មោះម្ចាស់កម្មសិទ្ធិយ៉ាងច្បាស់លាស់ ដែលត្រៀមតែនឹងទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប្លង់រឹង)តែប៉ុណ្ណោះ ដោយពុំមានភាគីណាមួយមកតវ៉ានោះទេ ដែលនេះបង្ហាញឲ្យឃើញថាសិទ្ធិលើកម្មសិទ្ធិគឺបានចុះបញ្ជីត្រឹមត្រូវ ហើយការកាន់កាប់អចលនវត្ថុរបស់សហដើមចោទនេះ គឺធ្វើឡើងដោយសន្តិវិធី ដឹងឮជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ដោយសុចរិត និងគ្មានកំហុស ។

ចំពោះប្រាក់ប្រដាប់ក្តី គឺសហចុងចម្លើយ ជាអ្នកទទួលបន្ទុក ដោយហេតុថារាល់ការចំណាយផ្សេងៗទៅលើបណ្តឹងនេះ គឺជាកំហុសរបស់សហចុងចម្លើយទាំងស្រុង ។

ក្នុងនាមខ្លួនជាអ្នកតំណាងដោយអាណត្តិឲ្យសហដើមចោទ សូមឲ្យតុលាការមេត្តាធ្វើការរកយុត្តិធម៌ និងចេញសេចក្តីសម្រេចតាមការទាមទាររបស់កូនក្តីខ្លួនដោយក្តីអនុគ្រោះ ។

### ២.២.២-ការអះអាងរបស់សហចុងចម្លើយ

-សហចុងចម្លើយឈ្មោះ [redacted] គឹមឈឿប, ឈ្មោះ [redacted] គឹមឆង, ឈ្មោះ [redacted] គឹមឈន់ និងឈ្មោះ [redacted] ឡឹម មិនបានបង្ហាញខ្លួន(អវត្តមាន) តែតុលាការបានបញ្ជូនដីកាកោះនិងឯកសារផ្សេងៗដែលពាក់ព័ន្ធតាមការផ្សាយជាសាធារណៈរួចរាល់ហើយដែលចាត់ជាការជូនដំណឹងដល់សហចុងចម្លើយតាមនីតិវិធីច្បាប់ ។

### ២.២.៣-ឥស្សតាងជាសាក្សីរបស់សហដើមចោទ

-សាក្សីឈ្មោះ [redacted] រី បានអះអាងថា៖ខ្លួនបានរស់នៅក្នុងភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម ដែលកាលពីមុនជាភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ចាប់តាំងពីឆ្នាំ១៩៧៩ រហូតមកដល់សព្វថ្ងៃនេះ ដោយពុំបានផ្លាស់ប្តូរទីលំនៅទៅរស់នៅទីកន្លែង ណាផ្សេងទេ ។ ខ្លួនស្គាល់ឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] លាំ ចាប់តាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ ព្រោះជាអ្នករស់នៅភូមិឃុំជាមួយគ្នា ប៉ុន្តែចំងាយពីផ្ទះខ្លួនទៅផ្ទះរបស់ឈ្មោះ [redacted] ឈឿម និងឈ្មោះ [redacted] លាំ ប្រហែលជាង ៥០ម៉ែត្រ។ ដោយកាលពីមុន ដីនោះពួកគាត់ធ្វើស្រែចំការ ក្រោយមកឈ្មោះ [redacted] ឈឿម គាត់ក៏បានដាំដើមស្វាយជាច្រើនដើម និងសាងសង់ផ្ទះរស់នៅលើដីនោះតែម្តង រហូតមក

ដល់សព្វថ្ងៃនេះ ហើយគាត់ក៏មិនបានផ្លាស់ប្តូរទីលំនៅទៅរស់នៅកន្លែងណាផ្សេងដែរ ហើយឈ្មោះ [redacted] ខេង ថែមទាំងបានធ្វើរបងហ៊ុំព័ទ្ធដី និងធ្វើឃ្លាំងផ្ទុកអីវ៉ាន់យ៉ាងធំ មិនដែលឃើញមានអាជ្ញាធរណាទៅរករឿងផង ព្រោះជាដីរបស់គាត់ ម្យ៉ាងប្រហែលជា ៣ ទៅ ៤ឆ្នាំមុន មានក្រុមនិសិត្ស សហការណ៍ជាមួយមន្ត្រីជំនាញ និងអាជ្ញាភូមិឃុំ បានចុះទៅ វាស់វែងលើដីភូមិចុងកៅស៊ូ (សព្វថ្ងៃភូមិផ្លូកអណ្តូង) ដែលពួកខ្លួនរស់នៅ ដើម្បីធ្វើប័ណ្ណកម្មសិទ្ធិ ដោយមន្ត្រី ជំនាញបានចេញលិខិតសំគាល់លេខក្បាលដី និងព្រំប្រទល់ដីមកឱ្យប្រជាជន តាមកម្មសិទ្ធិរៀង១ខ្លួន។ ចាប់តាំងពីខ្លួនស្គាល់ឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] ឈាំ មក ខ្លួនមិនដែលបានឃើញថាមានអ្នកណា ឬជនណាទៅតវ៉ាថា ដីដែលឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] ឈាំ រស់នៅនោះជាដីរបស់ពួកគេ ឬដីអ្នកផ្សេងដែរ គឺឃើញតែស្ងប់ស្ងាត់រហូត ហើយ ក៏មិនដែលឃើញមានអាជ្ញាធរណាទៅរករឿងគាត់ ឬហាមឃាត់គាត់ដែរ ព្រោះជាដីរបស់គាត់ ម្យ៉ាងទៀតដីនៅចំណុចនោះ គឺពួកខ្លួនមានគ្នាប្រហែល ១២គ្រួសារ ទៅរស់នៅ និងកាន់កាប់ធ្វើស្រែមុនគេ ចាប់តាំងពីថ្ងៃរំដោះពីសម័យប៉ុលពតមកតាំងពីមិនទាន់មានផ្សារលើធំថ្មី កើតឡើង។ ដីរបស់ឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] ឈាំ ដោយកាលពីមុនស្ថិតនៅ ក្នុងភូមិចុងកៅស៊ូ ហើយសព្វថ្ងៃត្រូវបានប្តូរមកជាភូមិផ្លូកអណ្តូងវិញហើយ ដូចដីរបស់ខ្លួនដែរ។

-សាក្សីឈ្មោះ [redacted] ហឿម បានឆ្លើយថា:ខ្លួនបានរស់នៅក្នុងភូមិផ្លូកអណ្តូង សង្កាត់ស្លក្រាម ដែលកាលពីមុនជាភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ចាប់តាំងពីឆ្នាំ១៩៩៣ រហូតមកដល់សព្វថ្ងៃនេះ ដោយពុំបានផ្លាស់ប្តូរទីលំនៅទៅរស់នៅទីកន្លែង ណាផ្សេងទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] ឈាំ ចាប់តាំងពីឆ្នាំ១៩៩៣ មកម្ល៉េះ ព្រោះជាអ្នករស់នៅភូមិឃុំជាមួយគ្នា ប៉ុន្តែចំងាយពីផ្ទះខ្លួនទៅផ្ទះរបស់ឈ្មោះ [redacted] ឈឿម និងឈ្មោះ [redacted] ឈាំ ប្រហែលជាង ៧០ម៉ែត្រ។ ដោយកាលពីមុន ដីនោះពួកគាត់ធ្វើស្រែចំការ ដូចដីខ្លួនដែរ ។ ក្រោយមកឈ្មោះ [redacted] ឈឿម គាត់ក៏បានដាំដើមស្វាយជាច្រើនដើម និងសាងសង់ផ្ទះរស់នៅលើដីនោះតែម្តងរហូតមកដល់សព្វថ្ងៃនេះ ហើយគាត់ក៏មិនបានផ្លាស់ប្តូរទីលំនៅទៅរស់នៅកន្លែងណាផ្សេងដែរ ហើយឈ្មោះ [redacted] ខេង ថែមទាំងបានធ្វើរបងហ៊ុំព័ទ្ធដី និងធ្វើឃ្លាំងផ្ទុកអីវ៉ាន់យ៉ាងធំ មិនដែលឃើញមានអាជ្ញាធរណាទៅរករឿងផង ព្រោះជាដីរបស់គាត់ ។ ហើយដីនៅតំបន់ភូមិផ្លូកអណ្តូង (ពីមុនភូមិចុងកៅស៊ូ) នោះមានខាងសុរិយោដីខេត្តសៀមរាប និងអាជ្ញាភូមិឃុំ បានចុះទៅវាស់វែងលើដីដែលពួកខ្លួនរស់នៅ ដើម្បីធ្វើប័ណ្ណកម្មសិទ្ធិ ដោយមន្ត្រីជំនាញបានចេញលិខិតសំគាល់លេខក្បាលដី និងព្រំប្រទល់ដីមកឱ្យប្រជាជនតាមកម្មសិទ្ធិរៀង១ខ្លួន។ចាប់តាំងពីខ្លួនស្គាល់ឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] ឈាំ មក ខ្លួនមិនដែលបានឃើញថាមានអ្នកណា ឬជនណាទៅតវ៉ាថា ដីដែលឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] ឈាំ រស់នៅនោះជាដីរបស់ពួកគេ ឬដីអ្នកផ្សេងដែរ គឺឃើញតែស្ងប់ស្ងាត់រហូត ហើយ ក៏មិនដែលឃើញមានអាជ្ញាធរណាទៅរករឿងគាត់ ឬហាមឃាត់គាត់ដែរ ព្រោះជាដីរបស់គាត់។ ដីរបស់ឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] ឈាំ

ដោយកាលពីមុនស្ថិតនៅ ក្នុងភូមិចុងកោស៊ូ ហើយសព្វថ្ងៃត្រូវបានប្តូរមកជាភូមិផ្លូកអណ្តូងវិញហើយ ដូចដីរបស់ខ្លួនដែរ។

-សាក្សីឈ្មោះ [redacted] ឡុំ បានអះអាងថា:ខ្លួនបានរស់នៅក្នុងភូមិផ្លូកអណ្តូង សង្កាត់ស្តុក្រាម ដែលកាលពីមុនជាភូមិចុងកោស៊ូ សង្កាត់ស្តុក្រាម ចាប់តាំងពីឆ្នាំ១៩៧៩ ប៉ុន្តែនៅក្នុងឆ្នាំ២០០៨ ខ្លួនបានផ្លាស់ទៅរស់នៅភូមិទ្រាំង សង្កាត់ស្តុក្រាម រយៈពេល៣ឆ្នាំ ទើបត្រឡប់មករស់នៅភូមិចុងកោស៊ូ វិញ ដែលសព្វថ្ងៃជាភូមិផ្លូកអណ្តូង។ ខ្លួនស្គាល់ឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] លាំ ចាប់តាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ ព្រោះជាអ្នករស់នៅភូមិឃុំជាមួយគ្នា ប៉ុន្តែចំងាយពីផ្ទះខ្លួនទៅផ្ទះរបស់ឈ្មោះ [redacted] ឈឿម និងឈ្មោះ [redacted] លាំ ប្រហែលជាង ១០០ម៉ែត្រ។ ដោយកាលពីមុន ដីនោះពួកគាត់ធ្វើស្រែចំការ ក្រោយមកឈ្មោះ [redacted] ឈឿម គាត់ក៏បានដាំដើមស្វាយជាច្រើនដើម និងសាងសង់ផ្ទះរស់នៅលើដីនោះតែម្តង រហូតមកដល់សព្វថ្ងៃនេះ ហើយគាត់ក៏មិនបានផ្លាស់ប្តូរទីលំនៅទៅរស់នៅកន្លែងណាផ្សេងដែរ ហើយឈ្មោះ [redacted] ខេង ថែមទាំងបានធ្វើរបងហ៊ុំព័ទ្ធដី និងធ្វើឃ្លាំងផ្ទុកអីវ៉ាន់យ៉ាងធំ មិនដែលឃើញមានអាជ្ញាធរណាទៅរករឿងផង ព្រោះជាដីរបស់គាត់។ ចាប់តាំងពីខ្លួនស្គាល់ឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] លាំ មក ខ្លួនមិនដែលបានឃើញថាមានអ្នកណា ឬជនណាទៅតវ៉ាថា ដីដែលឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] លាំ រស់នៅនោះជាដីរបស់ពួកគេ ឬដីអ្នកផ្សេងដែរ គឺឃើញតែស្ងប់ស្ងាត់រហូត ហើយ ក៏មិនដែលឃើញមានអាជ្ញាធរណាទៅរករឿងគាត់ ឬហាមឃាត់គាត់ដែរ ព្រោះជាដីរបស់គាត់។ ដីរបស់ឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] លាំ ដោយកាលពីមុនស្ថិតនៅ ក្នុងភូមិចុងកោស៊ូ ហើយសព្វថ្ងៃត្រូវបានប្តូរមកជាភូមិផ្លូកអណ្តូងវិញហើយ ដូចដីរបស់ខ្លួនដែរ។

-សាក្សីឈ្មោះ [redacted] ប៉ាយ៉ុម បានអះអាងថា: ខ្លួនបានរស់នៅក្នុងភូមិផ្លូកអណ្តូង សង្កាត់ស្តុក្រាម ដែលកាលពីមុនជាភូមិចុងកោស៊ូ សង្កាត់ស្តុក្រាម ចាប់តាំងពីឆ្នាំ១៩៨៣ រហូតមកដល់សព្វថ្ងៃនេះ ដោយពុំដែលធ្លាប់បានផ្លាស់ប្តូរទីលំនៅទៅរស់នៅ ទីកន្លែងណាផ្សេងទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] លាំ ចាប់តាំងពីឆ្នាំ១៩៨៣ មកម្ល៉េះ ចាប់តាំងពីខ្លួនទៅរស់នៅភូមិចុងកោស៊ូ (សព្វថ្ងៃភូមិផ្លូកអណ្តូង) ព្រោះដីគាត់ និងដីរបស់ខ្លួនជាប់ព្រំប្រទល់គ្នា ដោយកាលពីមុន ដីនោះគាត់ធ្វើស្រែ បន្ទាប់មកគាត់ក៏បានដាំដើមស្វាយជាច្រើនដើម និងសាងសង់ផ្ទះរស់នៅ លើដីនោះតែម្តង រហូតមកដល់សព្វថ្ងៃនេះ ហើយគាត់ក៏មិនបានផ្លាស់ប្តូរទីលំនៅទៅរស់នៅកន្លែងណាផ្សេងដែរ។ ចាប់តាំងពីខ្លួនរស់នៅជាប់ព្រំដីគ្នាជាមួយឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] លាំ មក ខ្លួនមិនដែលបានឃើញថាមានអ្នកណា ឬជនណាទៅតវ៉ាថា ដីដែលឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] លាំ រស់នៅនោះជាដីរបស់ពួកគេ ឬដីអ្នកផ្សេងដែរ គឺឃើញតែស្ងប់ស្ងាត់រហូត ហើយឈ្មោះ [redacted] ខេង ថែមទាំងបានធ្វើរបងហ៊ុំព័ទ្ធដី និងធ្វើឃ្លាំងផ្ទុកអីវ៉ាន់យ៉ាងធំ មិនដែលឃើញមានអាជ្ញាធរណាទៅរក រឿងផង ព្រោះជាដីរបស់គាត់។ ដីរបស់ឈ្មោះ [redacted] ឈឿម, ឈ្មោះ

[redacted]ខេង និងឈ្មោះ[redacted]លាំ ដែលកាលពីមុនស្ថិតនៅ ក្នុងភូមិចុងកោស៊ូ ហើយសព្វថ្ងៃត្រូវបានប្តូរមកជាភូមិធ្លកអណ្តូងវិញហើយ ដូចដីរបស់ខ្លួនដែរ។

-សាក្សីឈ្មោះ [redacted] វ៉ាវុទ្ធ បានអះអាងថា:ខ្លួនបានរស់នៅក្នុងភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម ដែលកាលពីមុនជាភូមិចុងកោស៊ូ សង្កាត់ស្លក្រាម ចាប់តាំងពីឆ្នាំ១៩៨៤ ។ នៅឆ្នាំ១៩៩០ ខ្លួនបានធ្វើជាមេភូមិចុងកោស៊ូ រហូតដល់ឆ្នាំ២០១៧ ទើប ខ្លួនឈប់ធ្វើជាមេភូមិ។ ខ្លួនស្គាល់ឈ្មោះ [redacted] ឈឿម, ឈ្មោះ[redacted] ខេង និងឈ្មោះ [redacted]លាំ ព្រោះពួកគាត់ជា ប្រជាពលរដ្ឋរស់នៅភូមិចុងកោស៊ូ (សព្វថ្ងៃភូមិធ្លកអណ្តូង) ក្រោមការគ្រប់គ្រងរបស់ខ្លួនដែលកាលពីមុន ដែលខ្លួននៅធ្វើជាមេភូមិចុងកោស៊ូ។ ឈ្មោះ [redacted] ឈឿម, ឈ្មោះ[redacted] ខេង និងឈ្មោះ [redacted] លាំ ពួកគាត់ពិតជាមានដីនៅភូមិ ចុងកោស៊ូ (សព្វថ្ងៃភូមិធ្លកអណ្តូង) ដែលពួកគាត់បានកាន់កាប់ចាប់តាំងពីឆ្នាំ១៩៧៩ ដូចរូបខ្ញុំបាទដែរ ហើយនៅ ឆ្នាំ១៩៨៩ ទើបរដ្ឋប្រកាសឱ្យប្រជាពលរដ្ឋទៅធ្វើលិខិតកាន់កាប់ដីធ្លី ដោយរដ្ឋកំណត់ថា ដីលំនៅដ្ឋាន ក្នុង ១គ្រួសារ ទទួលបានតែ ២០០០ម៉ែត្រការ៉េទេ ក្រៅពីនេះជាដីចំការ ឬដីស្រែ។ រហូតដល់ឆ្នាំ២០១៦ ទើបរដ្ឋប្រកាសឱ្យប្រជាពលរដ្ឋដែលរស់នៅភូមិចុងកោស៊ូ (សព្វថ្ងៃភូមិធ្លកអណ្តូង) ធ្វើបណ្ណ័កម្មសិទ្ធិលើដីរបស់ខ្លួនរៀង១ខ្លួន ដោយមាន មន្ត្រីជំនាញនៅមន្ទីរសុរិយោដីខេត្តសៀមរាប រួមជាមួយនឹងអាជ្ញាធរភូមិឃុំចុះវាស់វែងជូនប្រជាពលរដ្ឋ ព្រមទាំង បានចេញជាលិខិតសំគាល់លេខក្បាលដី និងទីតាំងព្រំប្រទល់ដីតាមម្ចាស់នីមួយៗផងដែរ។ ដីរបស់ឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted]ខេង និងឈ្មោះ [redacted] លាំ ដែលកាលពីមុនស្ថិតនៅ ក្នុងភូមិចុងកោស៊ូ ហើយសព្វថ្ងៃត្រូវបានប្តូរមកជាភូមិធ្លកអណ្តូងវិញហើយ ដូចដីរបស់ខ្លួនដែរ។ ខ្លួនស្គាល់ដីរបស់ឈ្មោះ [redacted] ឈឿម, ឈ្មោះ[redacted]ខេង និងឈ្មោះ[redacted]លាំ ព្រោះដីរបស់ ពួកគាត់ គឺនៅរំលងគ្នានឹងដីរបស់ខ្លួន ១ផ្លូវម្នាក់។

## ២.២.៤-ភស្តុតាងជាឯកសាររបស់សហដើមចោទ

១.ប្រដាសប័ណ្ណសម្គាល់ក្បាលដីលេខ:២៦៥ របស់ឈ្មោះ [redacted] ឈឿម និងឈ្មោះ [redacted] ឡាយ

២.លិខិតអះអាងប្រវត្តិដី របស់ឈ្មោះ [redacted] ឈឿម និងឈ្មោះ[redacted] ឡាយ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១៥ ដោយមានបញ្ជាក់លេខ:១២៨៩ សស ក្រ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៥ របស់ចៅសង្កាត់ស្លក្រាម។

៣.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ: ១៨០០០៨០៦៧ ចុះថ្ងៃទី២៨ ខែ សីហា ឆ្នាំ២០០០ របស់ឈ្មោះ [redacted] ឈឿម ។

៤.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: ១៨០៦៤៥៦២២ ចុះថ្ងៃទី១៣ ខែ វិច្ឆិកា ឆ្នាំ២០១៣ របស់ឈ្មោះ[redacted] ឡាយ ។

៥.ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី របស់ឈ្មោះ [redacted] ឈឿម និងឈ្មោះ [redacted] ឡាយ ចុះថ្ងៃទី០២ ខែ មិថុនា ឆ្នាំ ២០០៨ ដោយបញ្ជាក់លេខ:១៣៦ ច កស ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៨ របស់មេភូមិចុងកោស៊ូ ។



Scanned with CamScanner

៦.កិច្ចសន្យា ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៨ ដោយមានបញ្ជាក់លេខ:១៣៦ ច ក ស ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៨ របស់មេភូមិចុងកៅស៊ូ ។

៧.ប្រកាសប័ណ្ណសម្គាល់ក្បាលដីលេខ:២៧១ របស់ឈ្មោះ [redacted] លាំ

៨.លិខិតអះអាងប្រវត្តិដី របស់ឈ្មោះ [redacted] លាំ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១៥ ដោយមានបញ្ជាក់លេខ:១១៦៥ សស ក្រ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ របស់ចៅសង្កាត់ស្លក្រាម។

៩.លិខិតធ្វើអំណោយផ្តាច់ ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៥ មានបញ្ជាក់លេខ:៦១៥ ច កស ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ ចេញដោយភូមិចុងកៅស៊ូ និងមានបញ្ជាក់លេខ:៦៥៧ សស ក្រ ចុះថ្ងៃទី០៣ ខែ មេសា ឆ្នាំ ២០១៥ ចេញដោយចៅសង្កាត់ស្លក្រាម ។

១០.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: ១៨០៦៤៥៦១៤ ចុះថ្ងៃទី១៣ ខែ វិច្ឆិកា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] លាំ ។

១១.ប្រកាសប័ណ្ណសម្គាល់ក្បាលដីលេខ:២៧២ របស់ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] ស្រីពេជ្រ

១២.លិខិតអះអាងប្រវត្តិដី របស់ឈ្មោះ [redacted] លាំ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១៥ ដោយមានបញ្ជាក់លេខ:១១៦៥ សស ក្រ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ របស់ចៅសង្កាត់ស្លក្រាម។

១៣.លិខិតធ្វើអំណោយផ្តាច់ ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៥ មានបញ្ជាក់លេខ:៦១៥ ច កស ចុះថ្ងៃទី០១ ខែ មេសា ឆ្នាំ ២០១៥ ចេញដោយភូមិចុងកៅស៊ូ និងមានបញ្ជាក់លេខ:៦៥៧ សស ក្រ ចុះថ្ងៃទី០៣ ខែ មេសា ឆ្នាំ ២០១៥ ចេញដោយចៅសង្កាត់ស្លក្រាម ។

១៤.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: ០៦០៥២៥៣៩៧(០១) ចុះថ្ងៃទី២២ ខែ វិច្ឆិកា ឆ្នាំ២០១៧ របស់ឈ្មោះ [redacted] ខេង ។

១៥.សាលក្រមរដ្ឋប្បវេណីលេខ:២២ “ខ” ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦, សាលក្រមរដ្ឋប្បវេណីលេខ:២៣ “ខ” ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ និងសាលក្រមរដ្ឋប្បវេណីលេខ:២៤ “ខ” ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

## សំអាងហេតុ

### ១-ការវិនិច្ឆ័យចំពោះចំណុចទាមទារ

១.១-ចំពោះការសុំទាមទារ ត្រង់ចំណុចទី១. សុំទាមទារឲ្យជំនុំជម្រះសាជាថ្មី ចំពោះសាលក្រមរដ្ឋប្បវេណីលេខ:២២ “ខ” ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០០៦, លេខ:២៣ “ខ” ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ និងលេខ: ២៤ “ខ” ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០០៦ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ឃើញថាតុលាការបានពិចារណារួចហើយ ដូចមានសំអាងហេតុក្នុងដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មីលេខ:៤៧៩ /២០១៨ ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៨ ដោយយោងតាមបញ្ញត្តិមាត្រា៣១៨ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានចែងថា: បើដើមចោទ និង ចុងចម្លើយ បានទទួលនូវសាលក្រម ឬ សាលដីកា ដោយរួមគំនិតគ្នាក្នុងគោល

បំណងធ្វើឱ្យបាត់បង់សិទ្ធិ ឬផលប្រយោជន៍របស់តតិយជន តតិយជននោះ អាចធ្វើឧបាស្រ័យ ដោយបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលក្រម ឬសាលដីកាចុងក្រោយដែលបានចូលជាស្ថាពរនោះបាន ។ ក្នុងករណីនេះ ឃើញថាសហចុងចម្លើយ ពិតជាបានសហការគ្នាដោយប្រើគំនិតទុច្ចរិត ដើម្បីទទួលបានសាលក្រមខាងលើដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់សហដើមចោទ(ជាតតិយជន) ហើយការប្តឹងទាមទារឱ្យសុំជំនុំជម្រះសាជាថ្មីដោយសហដើមចោទនេះ គឺហៅថាការជំនុំជម្រះសាជាថ្មីកុំឱ្យមានការខូចខាតប្រយោជន៍។ ដូច្នេះការទាមទាររបស់សហដើមចោទ ក៏ដូចជាអ្នកតំណាងដោយអាណត្តិឱ្យសហដើមចោទ គឺមានភស្តុតាងនិងមូលហេតុត្រឹមត្រូវ ដែលតុលាការបានទទួលស្គាល់ការទាមទារនេះហើយ ។

១.២-ចំណែកការទាមទារត្រង់ចំណុចទី២.សុំបដិសេធចោលនូវសេចក្តីសម្រេចទាំងមូល នៃសាលក្រមរដ្ឋប្បវេណីលេខ: ២២ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦, លេខ:២៣ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ និងលេខ: ២៤ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០០៦ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ តុលាការឃើញថា:ខ្លឹមសារនៃសេចក្តីសម្រេចទាំងមូលនៃសាលក្រមរដ្ឋប្បវេណីទាំងបីខាងលើនេះ បានធ្វើការសម្រេចដោយបានបំពានសិទ្ធិ និងខូចខាតប្រយោជន៍របស់សហដើមចោទយ៉ាងធ្ងន់ធ្ងរ ហើយមូលហេតុដែលទាមទារឱ្យតុលាការជំនុំជម្រះសាជាថ្មី គឺតុលាការបានទទួលស្គាល់ហើយថាពិតជាមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីប្រាកដមែន ដូចមានក្នុងសំអាងហេតុចំណុច១.១ ខាងលើ។ ជាពិសេស ការពិនិត្យទៅលើការទាមទារនេះ គឺមានផលប្រយោជន៍សម្រាប់សហដើមចោទ ផ្ទុយពីសាលក្រមរដ្ឋប្បវេណីទាំងបីខាងលើ ដែលសម្រេចទៅមានភាពមិនត្រឹមត្រូវ ហើយលទ្ធផលដែលសហដើមចោទទទួលបានគឺបាត់បង់ផលប្រយោជន៍យ៉ាងខ្លាំងពីសាលក្រមដើមនេះ ដូច្នេះតុលាការត្រូវលុបចោលនូវសាលក្រមដើម ហើយត្រូវវិនិច្ឆ័យលើអង្គសេចក្តីបន្ថែមទៀតបាន ដើម្បីកុំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់សហដើមចោទ ។ ដូច្នេះការទាមទាររបស់អ្នកតំណាងដោយអាណត្តិឱ្យសហដើមចោទ មានភស្តុតាងនិងមូលហេតុត្រឹមត្រូវ ដែលតុលាការធ្វើការវិនិច្ឆ័យបាន យោងតាមបញ្ញត្តិមាត្រា ៣១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

១.៣-ជាមួយគ្នានេះដែរ ការទាមទារត្រង់ចំណុចទី៣.សុំលុបចោលការអនុវត្តដោយបង្ខំលើសំណុំរឿងអនុវត្តដោយបង្ខំលេខ:១៦, លេខ:១៧ និងលេខ:១៨ ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប តុលាការឃើញថាការចុះអនុវត្តដោយបង្ខំរបស់តំណាងអយ្យការ និងជាមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា គឺធ្វើឱ្យប៉ះពាល់ដល់សិទ្ធិលើកម្មសិទ្ធិ ឬសិទ្ធិផ្សេងៗទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬការប្រគល់ចំពោះវត្ថុនៃការអនុវត្តដោយបង្ខំខាងលើរបស់សហដើមចោទ ។ មួយវិញទៀត តុលាការបានពិចារណារួចហើយអំពីការជំនុំជម្រះសាជាថ្មី ដូចក្នុងចំណុច ១.១ និងការបដិសេធចោលនូវសេចក្តីទាំងមូលនៃសាលក្រមរដ្ឋប្បវេណីលេខ: ២២ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦, លេខ:២៣ "ខ" ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ និងលេខ: ២៤ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០០៦ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ដូចមានក្នុងចំណុច១.២ខាង



Scanned with CamScanner

លើ ។ តុលាការបានពិចារណាលើការបដិសេធចោលសាលក្រមរដ្ឋប្បវេណីទាំងបីខាងលើរួចហើយ ដែលជាលិខិតអនុវត្តដ៏សំខាន់នៃសំណុំរឿងអនុវត្តដោយបង្ខំខាងលើនេះ ដែលត្រូវផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងជំនុំជម្រះសាជាថ្មីហើយអាជ្ញាសាលាដែលជាស្ថាប័នអនុវត្ត ត្រូវផ្អាកការអនុវត្តដោយបង្ខំ ហើយត្រូវលុបចោលការចាត់ចែងការអនុវត្ត យោងតាមបញ្ញត្តិមាត្រា ៣៦៦ និងមាត្រា ៣៧០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ដូច្នេះការទាមទារខាងលើរបស់ភាគីដើមចោទ មានភស្តុតាងនិងមូលហេតុត្រឹមត្រូវ ដែលតុលាការធ្វើការវិនិច្ឆ័យបាន ។

១.៤-មួយវិញទៀត ការទាមទារត្រង់ចំណុចទី៤.សុំទទួលស្គាល់លើកម្មសិទ្ធិនៅលើក្បាលដីលេខ:**២៦៥** មានទីតាំងស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ជារបស់ឈ្មោះម្ចាស់ដី: [redacted] **ឃឿម** និង [redacted] ឡាយ ដែលមានព្រំប្រទល់ខាងជើង:ផ្លូវ, ខាងត្បូង:ផ្លូវ, ខាងកើត:ឈ្មោះ [redacted] ឈឹមឆន(២៦៦) និងខាងលិច: [redacted] លាំ (២៧១) ;ផ្លូវ , ក្បាលដីលេខ:**២៧១** មានទីតាំងស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ជារបស់ឈ្មោះម្ចាស់ដី: [redacted] លាំ ដែលមានព្រំប្រទល់ខាងជើង:ឈ្មោះ [redacted] ប៉ាយយ៉ុម(២៦៤), ខាងត្បូង:ផ្លូវ, ខាងកើត [redacted] ឡាយ (២៦៥) និង ខាងលិច: [redacted] ខេង (២៧២) និងក្បាលដីលេខ:**២៧២** មានទីតាំងស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ជារបស់ឈ្មោះម្ចាស់ដី: [redacted] **ខេង** និង [redacted] ស្រីពេជ្រ ដែលមានព្រំប្រទល់ខាងជើង:ឈ្មោះ [redacted] ប៉ាយយ៉ុម(២៦៤), ខាងត្បូង:ផ្លូវ, ខាងកើត:ឈ្មោះ [redacted] លាំ (២៧១) និងខាងលិច (៣៧៦) ចេញដោយមន្ត្រីវាស់វែងនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប តុលាការឃើញថាសហដើមចោទមានបង្កាន់ដៃក្បាលដី ដែលចេញដោយអាជ្ញាធរ មានសមត្ថកិច្ចត្រឹមត្រូវតាមច្បាប់ ហើយបញ្ជាក់លេខក្បាលដី និងឈ្មោះម្ចាស់កម្មសិទ្ធិករយ៉ាងច្បាស់លាស់ ដែលត្រៀមតែនឹងទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ(ប្លង់រឹង)តែប៉ុណ្ណោះ ដោយពុំមានភាគីណាមួយមកតវ៉ានោះទេ ដែលនេះបង្ហាញឱ្យឃើញថាសិទ្ធិលើកម្មសិទ្ធិគឺបានចុះបញ្ជីត្រឹមត្រូវ ហើយការកាន់កាប់អចលនវត្ថុរបស់សហដើមចោទនេះ គឺធ្វើឡើងដោយសន្តិវិធី ដឹងឮជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ដោយសុចរិត និងគ្មានកំហុស ។ មួយវិញទៀតសហដើមចោទបានធ្វើលិខិតអះអាងប្រវត្តដី ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ ដែលមានសាក្សីមានដីជាប់ព្រំគ្នា និងបានចុះហត្ថលេខាប្រថាប់ត្រា ដោយលោកមេភូមិ មេឃុំត្រឹមត្រូវផងដែរ យោងតាមបញ្ញត្តិមាត្រា ១៣៨ , មាត្រា ១៦០ និងមាត្រា ១៦២ នៃក្រមរដ្ឋប្បវេណី ។ ដូច្នេះការទាមទាររបស់សហដើមចោទ មានភស្តុតាងនិងមូលហេតុត្រឹមត្រូវ ដែលតុលាការធ្វើការវិនិច្ឆ័យបាន ។

២-យោងតាមសាក្សីឈ្មោះ, [redacted] រី, ឈ្មោះ [redacted] **ហឿម**, ឈ្មោះ [redacted] ឡុំ, ឈ្មោះ [redacted] **ប៉ាយ៉ុម** និងឈ្មោះ [redacted] **វ៉ាវុទ្ធ** មានអះអាងស្រដៀងគ្នាថា: "....ចាប់តាំងពីពួកខ្លួនរស់នៅជាប់ព្រំដីគ្នាជាមួយឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] លាំ មក ខ្លួនមិនដែលបានឃើញថាមានអ្នកណា ឬជនណាទៅតវ៉ាថាដីដែលឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] លាំ រស់នៅនោះជាដីរបស់ពួកគេ ឬដីអ្នកផ្សេងដែរ គឺឃើញតែស្ងប់ស្ងាត់រហូត ហើយឈ្មោះ [redacted] ខេង ថែមទាំងបានធ្វើរបងហ៊ុំព័ទ្ធដី និងធ្វើឃ្លាំងផ្ទុកអីវ៉ាន់យ៉ាងធំ

មិនដែលឃើញមានអាជ្ញាធរណាទៅរក រឿងផង ព្រោះជាដីរបស់គាត់។ ដីរបស់ឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] ណាំ ដែលកាលពីមុនស្ថិតនៅ ក្នុងភូមិចុងកៅស៊ូ ហើយសព្វថ្ងៃត្រូវបានប្តូរមកជាភូមិផ្លកអណ្តូងវិញហើយ ដូចដីរបស់ពួកខ្លួនដែរ។ ឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] ណាំ ពួកគាត់ពិតជាមានដីនៅភូមិចុងកៅស៊ូ (សព្វថ្ងៃភូមិផ្លកអណ្តូង) ដែលពួកគាត់បានកាន់កាប់ចាប់តាំងពីឆ្នាំ១៩៧៩ ដូចរូបពួកខ្លួនបាទដែរ ហើយនៅ ឆ្នាំ១៩៨៩ ទើបរដ្ឋប្រកាសឱ្យប្រជាពលរដ្ឋទៅធ្វើលិខិតកាន់កាប់ដីធ្លី ដោយរដ្ឋកំណត់ថា ដីលំនៅដ្ឋាន ក្នុង ១គ្រួសារ ទទួលបានតែ ២០០០ម៉ែត្រការ៉េទេ ក្រៅពីនេះជាដីចំការ ឬដីស្រែ។ រហូតដល់ឆ្នាំ២០១៦ ទើបរដ្ឋប្រកាសឱ្យប្រជាពលរដ្ឋដែលរស់នៅភូមិចុងកៅស៊ូ (សព្វថ្ងៃភូមិផ្លកអណ្តូង) ធ្វើបណ្ណ័កម្មសិទ្ធិលើដីរបស់ពួកខ្លួនរៀងៗខ្លួន ដោយមានមន្ត្រីជំនាញនៅមន្ទីរសុរិយោដីខេត្តសៀមរាប រួមជាមួយនឹងអាជ្ញាធរភូមិឃុំចុះវាស់វែងជូនប្រជាពលរដ្ឋ ព្រមទាំងបានចេញជាលិខិតសំគាល់លេខក្បាលដី និងទីតាំងព្រំប្រទល់ដីតាមម្ចាស់នីមួយៗផងដែរ។ ដីរបស់ឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] ណាំ ដែលកាលពីមុនស្ថិតនៅក្នុងភូមិចុងកៅស៊ូ ហើយសព្វថ្ងៃត្រូវបានប្តូរមកជាភូមិផ្លកអណ្តូងវិញហើយដូចដីរបស់ខ្លួនដែរ ។ នេះបានន័យថាដីរបស់ឈ្មោះ [redacted] ឈឿម, ឈ្មោះ [redacted] ខេង និងឈ្មោះ [redacted] ណាំ ពិតជាមានទីតាំងដូចការអះអាងនិងពិតជារបស់ពួកខ្លួនទាំងបីនាក់ដូចការទាមទារប្រាកដមែន ។ ផ្ទុយទៅវិញ សហចុងចម្លើយឈ្មោះ [redacted] **គឹមឈឿប** ,ឈ្មោះ [redacted] **គឹមផង**, ឈ្មោះ [redacted] **គឹមឈន់** និងឈ្មោះ [redacted] **ឡូម** ពុំមានអចលនវត្ថុ(ដីធ្លី)នៅទីតាំងខាងលើ ហើយក៏ពុំមានអ្នកណាស្គាល់ពួកខ្លួននោះដែរ ។

៣-សហចុងចម្លើយឈ្មោះ [redacted] គឹមឈឿប, ឈ្មោះ [redacted] គឹមផង, ឈ្មោះ [redacted] គឹមឈន់ និងឈ្មោះ [redacted] ឡូម ពុំបានបង្ហាញខ្លួន តែតុលាការបានបញ្ជូនដីកាកោះនិងឯកសារផ្សេងៗដែលពាក់ព័ន្ធ តាមការផ្សាយជាសាធារណៈរួចរាល់ហើយដែលចាត់ជាការជូនដំណឹងដល់សហចុងចម្លើយតាមនីតិវិធីច្បាប់ ។ ដូច្នេះតុលាការចាត់ទុកថាសហចុងចម្លើយ បានសារភាពតាមសេចក្តីថ្លែងការណ៍របស់សហដើមចោទ ដែលទាក់ទងនឹងអង្គហេតុនិងការទាមទារ យោងតាមបញ្ញត្តិមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៤-តាមការអះអាងរបស់មេធាវីតំណាងដោយអាណត្តិ, សាក្សី និងពិនិត្យលើភស្តុតាងនានាក្នុងសំណុំរឿង ឃើញថាការប្តឹងសុំរបស់មេធាវីតំណាងដោយអាណត្តិសហដើមចោទ មានភស្តុតាងនិងមូលហេតុត្រឹមត្រូវដែលអាចឱ្យតុលាការពិចារណា និងវិនិច្ឆ័យតាមការទាមទារបាន ។

៥-ប្រាក់ប្រដាប់ក្តីតុលាការ គប្បីសម្រេចឱ្យសហចុងចម្លើយជាអ្នកទទួលបន្ទុក គឺជាកំហុសរបស់សហចុងចម្លើយទាំងស្រុង យោងតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១-ទទួលស្គាល់ការប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រមរដ្ឋប្បវេណីលេខៈ២២ “ខ” ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦, លេខៈ២៣ “ខ” ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ និងលេខៈ ២៤ “ខ” ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០០៦ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ តាមពាក្យបណ្តឹងសុំឱ្យជំនុំជម្រះសាជាថ្មី ចុះថ្ងៃទី១២

ខែកញ្ញា ឆ្នាំ២០១៧, ពាក្យសុំកែតម្រូវពាក្យបណ្ដឹង ចុះថ្ងៃទី០៦ ខែ មីនា ឆ្នាំ ២០១៨ និងពាក្យសុំកែតម្រូវពាក្យបណ្ដឹង ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១៨ ។

**២**-បដិសេធចោលនូវសេចក្ដីសម្រេចទាំងមូលនៃសាលក្រមរដ្ឋប្បវេណីលេខ:២២ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦, លេខ:២៣ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ និងលេខ: ២៤ "ខ" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ របស់តុលាការខេត្តសៀមរាប-ឧត្ដរមានជ័យ ។

**៣**-លុបចោលការអនុវត្តដោយបង្ខំលើសំណុំរឿងអនុវត្តដោយបង្ខំលេខ:១៦, លេខ:១៧ និងលេខ:១៨ ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ។

**៤**-ទទួលស្គាល់លើកម្មសិទ្ធិនៅលើក្បាលដីលេខ:**២៦៥** មានទីតាំងស្ថិតនៅភូមិចុងកៅស៊ូ(បច្ចុប្បន្ននៅភូមិផ្លូកអណ្ដូង) សង្កាត់ស្លក្រាម ក្រុងសៀមរាប ជារបស់ឈ្មោះម្ចាស់ដី: [redacted] **ឈឿម** និងឈ្មោះ [redacted] ឡាយ ដែលមានព្រំប្រទល់ខាងជើង:ផ្លូវ, ខាងត្បូង:ផ្លូវ, ខាងកើត:ឈ្មោះ [redacted] ឈឹមធន(២៦៦) និងខាងលិច: [redacted] ណាំ (២៧១) ; ផ្លូវ, ក្បាលដីលេខ:**២៧១** មានទីតាំងស្ថិតនៅភូមិចុងកៅស៊ូ(បច្ចុប្បន្ននៅភូមិផ្លូកអណ្ដូង) សង្កាត់ស្លក្រាម ក្រុងសៀមរាប ជារបស់ឈ្មោះម្ចាស់ដី: [redacted] ណាំ ដែលមានព្រំប្រទល់ខាងជើង: [redacted] ប៉ាយយ៉ុម(២៦៤), ខាងត្បូង:ផ្លូវ, ខាងកើត: [redacted] ឡាយ (២៦៥) និង ខាងលិច: [redacted] ខេង (២៧២) និងក្បាលដីលេខ:**២៧២** មានទីតាំងស្ថិតនៅភូមិចុងកៅស៊ូ(បច្ចុប្បន្ននៅភូមិផ្លូកអណ្ដូង) សង្កាត់ស្លក្រាម ក្រុងសៀមរាប ជារបស់ឈ្មោះម្ចាស់ដី: [redacted] **ខេង** និង [redacted] ស្រីពេជ្រ ដែលមានព្រំប្រទល់ខាងជើង:ឈ្មោះ [redacted] ប៉ាយយ៉ុម(២៦៤), ខាងត្បូង:ផ្លូវ, ខាងកើត:ឈ្មោះ [redacted] ណាំ (២៧១) និងខាងលិច (៣៧៦) ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប ។

**៥**-ប្រាក់ប្រដាប់ក្ដី ជាបន្ទុករបស់សហចុងចម្លើយ។

សាលក្រមនេះ ធ្វើការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០១៩ ។ ក្នុងករណីភាគីមិនសុខចិត្តនឹងសាលក្រមនេះ អាចប្ដឹងឧទ្ធរណ៍ក្នុងអំឡុងពេល១ខែ ចាប់ពីថ្ងៃទទួលអនុសារ:សាលក្រម ។ (មាត្រា២៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា:** [redacted]

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃសុក្រ ៣រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
សៀមរាប, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១៩
**ក្រឡាបញ្ជី**

**បានឃើញនិងឯកភាព**
**ចៅក្រមជំនុំជម្រះ**

[redacted]

[redacted]